# សេចក្តីថ្លែងការណ៍រួមរបស់សម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា
## ក្នុងឱកាស
## ទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី២៨ និងលើកទី១៨ នៅប្រទេសកម្ពុជា
## ក្រោមប្រធានបទ
## តួនាទីស្ត្រីជនជាតិដើមភាគតិចក្នុងការអភិរក្ស និងផ្ទេរចំណេះដឹងប្រពៃណី”

យើងខ្ញុំជាជនជាតិដើមភាគតិច ដែលជាអ្នកស្រុកដើម រស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្ហាញនូវការឯកភាពជាតិពន្ធ សង្គមវប្បធម៌ សេដ្ឋកិច្ច ប្រតិបត្តិតាមទំនៀមទម្លាប់ប្រពៃណី អត្តសញ្ញាណ និងការប្រើប្រាស់ជាសមូហភាព។ រដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែង និងយកចិត្តទុកចំពោះជនជាតិដើមភាគតិច រហូតបង្កើតអោយមានយន្តការជាតិ និងផ្តល់សច្ចាបណ្ណចុះហត្ថលេខាទទួលស្គាល់លើលិខិតុបករណ៍អន្តរជាតិ សម្រាប់អនុវត្តចំពោះជនជាតិដើមភាគតិចនៅកម្ពុជា។ មានដូចជារដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ដែលជាច្បាប់កំពូលរបស់ជាតិ មាត្រា៣១ ៤៥ ៤៧ មានច្បាប់មួយចំនួនដែលមានបង្ហាញស្ថានភាព និងសិទ្ធិជនជាតិដើមភាគតិច។ ច្បាប់ទាំងនោះរួមមាន ច្បាប់ភូមិបាលឆ្នាំ ២០០១ ច្បាប់ព្រៃឈើឆ្នាំ ២០០២ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨។ រដ្ឋាភិបាលមានក្រសួងចំនួន ១១ ដែលមានការពាក់ព័ន្ធ និងកំពុងតែធ្វើកិច្ចការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចក្នុងឆ្នាំ ២០០៩។

-សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពី៖សិទ្ធិជនជាតិដើមភាគតិច ឆ្នាំ២០០៧។

-អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទថ្ងៃទី០៣ខែកញ្ញា ឆ្នាំ១៩៨១។

-អនុសញ្ញា ILO លេខ ១១១ ស្តីពី "ការរើសអើងក្នុងការងារ និងមុខរបរ" ក្នុងឆ្នាំ ១៩៥៩ បានចែង អំពីសិទ្ធិកាន់កាប់ដីធ្លី និងធនធានធម្មជាតិតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច ។

-អនុសញ្ញាពលកម្មអន្តរជាតិ(ILO) លេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធ ត្រូវបាន ពិភាក្សានៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំចាប់តាំងពីឆ្នាំ១៩៨៦។

## សក្តានុពល និងការប្រឈមរបស់ស្ត្រី

នៅក្នុងបរិបទសង្គមជនជាតិដើមភាគតិច ស្ត្រីដើរតួរយ៉ាងសំខាន់នៅក្នុងកិច្ចការងារអភិវឌ្ឍន៍ទាំងនៅក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិ។ ស្ត្រីគឺជាធនធានមនុស្សដ៏សំខាន់បំផុតក្នុងការដឹកនាំ គ្រប់គ្រង ថែរក្សានូវអត្តសញ្ញាណ វប្បធម៌ ប្រពៃណី ដីធ្លី និងធនធានធម្មជាតិ ជាសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចក៏ដូចជាសង្គមជាតិទាំងមូល។ ចំណេះដឹងរបស់ស្ត្រីជនជាតិដើមភាគតិចមិនត្រឹមតែត្រូវបានអភិរក្សប៉ុណ្ណោះឡើយ ក៏ប៉ុន្តែត្រូវបាននឹងកំពុងផ្ទេរគ្រប់វិនាទីតាមរយៈការអនុវត្តសកម្មភាពជាក់ស្តែងក្នុងតួនាទីជីវភាពប្រចាំថ្ងៃ ក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិ។ ស្រីជនជាតិដើមភាគតិចជាអ្នកដឹកនាំក្នុងការធ្វើកសិកម្មប្រពៃណី ជាអ្នកស្វែងរកអុស ស្វែងរកប្រភពទឹកស្អាត និងថែទាំប្រភពទឹក ស្វែងរកបន្លែ ផ្លែឈើ ថ្នាំ ដែលបានទាញយកពីព្រៃ សម្រាប់ផ្គត់ផ្គង់នៅក្នុងគ្រួសារ។ បន្ថែមពីនេះស្ត្រីជនជាតិដើមភាគតិចក៏ជាអ្នកថែទាំសុខភាព សុខសុវត្ថិភាព សេដ្ឋកិច្ចគ្រួសារ និងជាអ្នកចែករំលែកចំណេះដឹងដ៏ល្អ

ទាក់ទងនឹងការថែទាំគ្រប់ពូជដំណាំ របៀបនៃការធ្វើកសិកម្ម និងការដកហូតអនុផលព្រៃឈើឱ្យមាននិរន្តរភាព។

ទោះបីជាស្ត្រីជនជាតិដើមភាគតិចមានចំណេះដឹង និងតួនាទីជាអ្នករកស៊ីចិញ្ចឹម អ្នកមើលថែរក្សាចំណេះដឹង អ្នកដឹកនាំ អ្នកការពារសិទ្ធិមនុស្ស និងជាអ្នកមានគុណតម្លៃរាប់មិនអស់ចំពោះក្រុមគ្រួសារ សហគមន៍ និងសង្គមយ៉ាងណាក៏ដោយ ក៏ពួកគេតែងតែទទួលរងនូវការរើសអើង ដោយផ្អែកលើមូលដ្ឋាននៃភេទ វណ្ណៈ ជាតិសាសន៍ និងស្ថានភាពសេដ្ឋកិច្ច ឋានៈសង្គម។ សិទ្ធិក្នុងការសម្រេចចិត្តដោយខ្លួនឯង ការគ្រប់គ្រងខ្លួនឯង ការគ្រប់គ្រងធនធានធម្មជាតិ និងដីដូនតាត្រូវបានរំលោភបំពានអស់ ជាច្រើនឆ្នាំមកហើយ។ ស្ត្រីជនជាតិដើមភាគតិច គឺជាអ្នកដឹកនាំនៅថ្នាក់មូលដ្ឋាន និងខ្លះនៅថ្នាក់ជាតិ ដែលតែងតែឈរនៅជួរមុខនៃការការពារទឹកដី វប្បធម៌ និងសហគមន៍របស់ខ្លួន។ ស្ត្រីជនជាតិដើមភាគតិចតែងតែជាតំណាងក្នុងការសម្រេចចិត្តយ៉ាងទូលំទូលាយ ការបញ្ចេញមតិ និងធ្វើសកម្មភាពញឹកញាប់ ដែលកាន់តែរងផលប៉ះពាល់អវិជ្ជមាន ទទួលរងគ្រោះ ការរើសអើង និងអំពើហិង្សាជាច្រើនបន្ថែមទៀតមកលើស្ត្រីជនជាតិដើមភាគតិច។ ចំណេះដឹង និងការតាំងចិត្តរបស់ស្ត្រីជនជាតិដើមភាគតិចក្នុងការអភិរក្ស អត្តសញ្ញាណ វប្បធម៌ ប្រពៃណី ជំនឿ សង្គមសហគមន៍ សមូហភាពដីធ្លី និងធនធានធម្មជាតិ ដោយសារការបំផ្លាញជាច្រើនរយៈពេលប៉ុន្មានឆ្នាំមកនេះ បានធ្វើឱ្យពួកគាត់មានការប្រឈមជាច្រើនដូចជា៖ ស្ត្រីដែលមានភាពសកម្មក្នុងការចូលរួម ដឹកនាំ ក្នុងកិច្ចការការពារអត្តសញ្ញាណ ដីធ្លី និងធនធានធម្មជាតិត្រូវទទួលរងនូវការគំរាមកំហែងពីសង្គមដែលមានការរើសអើងលើការចូលរួមសម្រេចចិត្តរបស់ស្ត្រី និងការអនុវត្តច្បាប់ដែលមិនមានយុត្តិធម៌សម្រាប់ស្ត្រី ដែលនាំឱ្យគាត់ទទួលរងនូវការប្តឹងផ្តល់ ចាប់ដាក់គុក បែកបាក់គ្រួសារ រស់នៅដោយជីវភាពខ្វះខាត គ្មានសុវត្ថិភាពផ្ទាល់ខ្លួន រស់នៅដោយភ័យខ្លាច មុខរបរប្រមូលផលអនុផលបានថយចុះ និងបាត់បង់ ហើយមិនតែប៉ុណ្ណោះវាបានធ្វើឱ្យអត្តសញ្ញាណកំពុងតែប្រឈមនឹងការបាត់បង់ព្រោះតែធនធានគ្រឹះរបស់ស្ត្រីត្រូវបានបំផ្លាញ សិទ្ធិរបស់ស្ត្រី សិទ្ធិគ្រប់គ្រងដីធ្លីត្រូវបានរឹតត្បិត ឬហាមឃាត់ដោយច្បាប់ និងអ្នកមានអំណាចមួយចំនួន។ ស្ត្រីក៏កំពុងប្រឈមបាត់បង់អត្តសញ្ញាណ ភាសា មត៌កសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច គ្មានសុវត្ថិភាព ដែលត្រូវបានគេដាក់ឱ្យសហគមន៍ខាងក្រៅរស់នៅលាយឡំជាមួយសហគមន៍ជនជាតិដើមភាគតិច។ ការដាក់ឱ្យសហគមន៍ខាងក្រៅចូលមករស់នៅលាយឡំបែបនេះ ស្ត្រីជនជាតិដើមភាគតិចធ្លាប់មានករណីរំលោភសេពសន្ថវៈ និងរំលោភសម្លាប់មកលើក្មេងស្រី និងស្ត្រីជនជាតិដើមភាគតិច បញ្ហាការប្រើប្រាស់គ្រឿងញៀនកាន់តែកើតឡើង ហើយការអនុវត្តនូវគោលនយោបាយជាតិស្តីពីភូមិ ឃុំ មានសុវត្ថិភាពនៅមានកម្រិតបំផុត។

## ការទាមទារ

យើងខ្ញុំជាសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា ដែលមានតំណាងបណ្តាញសហគមន៍ជនជាតិដើមភាគតិចមានដូចជា៖ ស្អូច ជង ស្ទួយ ព័រ គួយ ព្រៅ កាចក លុន គ្រឹង ទំពួន កាវែត ចារ៉ាយ ស្មៀង ថ្នូន ពូនង ក្រោល សមាគមស្ត្រីជនជាតិដើមភាគតិចកម្ពុជា សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា និងអង្គការគាំទ្រជនជាតិដើមភាគតិច។

សូមធ្វើការអំពាវនាវលើកទឹកចិត្តដល់ស្ត្រីជនជាតិដើមភាគតិចទូទាំងប្រទេសបន្តខិតខំ យកចិត្តទុកដាក់ពង្រឹងសមត្ថភាព បណ្ដាញជួយគ្នាឯង និងសម្លេងរបស់ខ្លួននៅគ្រប់និន្នាការ និងគ្រប់យន្តការ ដើម្បីឱ្យប្រាកដថាបានចូលរួមនូវរាល់ការសម្រេចចិត្តគ្រប់ជ្រុងជ្រោយ ក្នុងការដឹកនាំការអភិរក្ស ការផ្ទេរចំណេះដឹងប្រពៃណី និងអភិវឌ្ឍន៍ជនជាតិដើមភាគតិចឱ្យមាននិរន្តរភាពស្របតាមសិទ្ធិស្វ័យសម្រេចដែលមានចែងក្នុងសេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើមភាគតិច។

ជាមួយគ្នានេះដែរយើងខ្ញុំស្នើដល់បណ្ដាភ្នាក់ងារអភិវឌ្ឍន៍ជាតិ និងអន្តរជាតិបន្តយកចិត្តទុកដាក់ធ្វើការនិងផ្ដល់ការគាំទ្រដល់ស្ត្រីក្នុងការអភិវឌ្ឍ និងអភិរក្សសហគមន៍មូលដ្ឋានឱ្យបានពិតប្រាកដ។

ជាពិសេសយើងខ្ញុំស្នើសុំឱ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់ជំរុញក្នុងការអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិចឱ្យមាននិរន្តរភាពស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ និងសូមឱ្យរាជរដ្ឋាភិបាលជំរុញធន្ទះនយោបាយក្នុងការដាក់ឱ្យមានច្បាប់ទទួលស្គាល់ និងធានាការពារនូវចំណេះដឹង សិទ្ធិស្ត្រីជនជាតិដើមភាគតិច និងសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ហើយជាងនេះទៅទៀត សូមរាជរដ្ឋាភិបាលមេត្តាពង្រឹងការអនុវត្តច្បាប់ដែលបានទទួលស្គាល់នោះ ដោយគោរពសិទ្ធិ និងវប្បធម៌ប្រពៃណីជនជាតិដើមភាគតិចដូចដែលមានចែងក្នុងលិខិតតុបករណ៍ជាតិ និងអន្តរជាតិ ដើម្បីធានាថាស្ត្រីជនជាតិដើមភាគតិច និងសហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការសម្រេចចិត្ត មានកម្មសិទ្ធិដីធ្លីជាសមូហភាពទៅតាមការទាមទារ ឬតម្រូវការរបស់ជនជាតិដើមភាគតិច។ យើងខ្ញុំជនជាតិដើមភាគតិចរំពឹងថានឹងគ្មានខ្លឹមសារច្បាប់ និងការអនុវត្តច្បាប់ណាដែលមានការរើសអើង រឹតត្បិត ដកហូតសិទ្ធិលើ ដីធ្លីធនធានធម្មជាតិ វប្បធម៌ សង្គមសេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចឡើយ។

លើសពីនេះទៅទៀត សូមរាជរដ្ឋាភិបាល និងតុលាការ មេត្តាលុបបំបាត់គ្រប់ទម្រង់ គ្រប់រូបភាពនៃអំពើហិង្សា ការគំរាមកំហែង ការរឹតត្បិត ការលាបពណ៌ ការចោទប្រកាន់ ការចាប់ចង ការឃុំឃាំងមកលើជនជាតិដើមភាគតិចតាមអំពើចិត្តពីសំណាក់អាជ្ញាធររដ្ឋគ្រប់លំដាប់ថ្នាក់ចាប់ពីពេលនេះតទៅ។ យើងខ្ញុំសូមប្រាថ្នាឱ្យមានសុខសុវត្ថិភាពសង្គម ដោយគ្មានគ្រឿងញៀន ជាពិសេសកុំឱ្យមានអំពើរំលោភសេពសន្ថវៈ និងរំលោភសម្លាប់លើក្មេងស្រី និងស្ត្រីជនជាតិដើមភាគតិច។ សូមរាជរដ្ឋាភិបាលមេត្តាជម្រុញ និងពង្រឹងការស៊ើបអង្កេត និងចាប់ជនល្មើសទៅផ្ដន្ទាទោសតាមច្បាប់ដែលបានចែងជាធរមាន ចំពោះករណីរំលោភសេពសន្ថវៈ និងរំលោភសម្លាប់លើក្មេងស្រី និងស្ត្រីជនជាតិដើមភាគតិចអោយមានប្រសិទ្ធិភាព និងយុត្តិធម៌បំផុត។។

ស្របគ្នានេះដែរ យើងខ្ញុំសុំសំណូមពរដល់រាជរដ្ឋាភិបាលធ្វើការជម្រុញ និងលើកកម្ពស់ទីផ្សាររបស់សហគមន៍ជនជាតិដើមភាគតិច ដើម្បីចូលរួមចំណែកកាត់បន្ថយការជំពាក់បំណុលធនាគារ និងធានាឱ្យបាននូវស្ថេរភាពសេដ្ឋកិច្ចរបស់សហគមន៍ជនជាតិដើមភាគតិចល្អប្រសើរ។

យើងខ្ញុំក៏សូមទាមទារឱ្យក្រសួងយុត្តិធម៌ និងចៅក្រម មេត្តាពង្រឹងការអនុវត្តច្បាប់ និង ធ្វើការស្វែងយល់ពីសិទ្ធិ ច្បាប់ ដែលមានចែងអំពីការទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិច ដើម្បីធានាថាយើងខ្ញុំជាជនរងគ្រោះទទួលបាននូវការជំនុំជម្រះ និងការកាត់ក្ដីប្រកបដោយយុត្តិធម៌។